# បទកុសលមាណវជាតក



## ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**កុល ផេង** **ព.ស. ២៥៦៤**



យេន សិញ្ចន្តិ ទុក្ខិតំ
យេន សិញ្ចន្តិ អាតុរំ
តស្ស មជ្ឈេ មរិស្សាមិ
ជាតំ សរណតោ ភយំ ។

ពួកជនតែងស្រោចនូវបុគ្គលមានទុក្ខដោយទឹកណា តែងស្រោចនូវបុគ្គលដែលមានសេចក្ដីក្រវល់ក្រវាយដោយទឹកណា យើងគង់នឹងស្លាប់ ក្នុងកណ្ដាលទឹកនោះ ភ័យកើតមកអំពីវត្ថុជាទីពឹងហើយ ។

# បទកុសលមាណវជាតក

រៀបរៀងដោយ

*បណ្ឌិត* **កុល ផេង**

សីល សមាធិ បញ្ញា

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

**ព.ស. ២៥៦៤**

| | |
|---|---|
| ឈ្មោះសៀវភៅ | **បទកុសលមាណវជាតក** |
| រៀបរៀងដោយ | បណ្ឌិត **កុល ផេង**<br>ប្រធានពុទ្ធិកបណ្ឌិតសភា<br>នៃសាកលវិទ្យាល័យ<br>បញ្ញាសាស្ត្រកម្ពុជា |
| ទីតាំងធ្វើ | ពុទ្ធិកបណ្ឌិតសភា |
| ការផ្សាយ | របស់ពុទ្ធិកបណ្ឌិតសភា |
| រក្សាសិទ្ធិ | ពុទ្ធិកបណ្ឌិតសភា |
| កាលបរិច្ឆេទ | ថ្ងៃព្រហស្បតិ៍ ៤ រោច ខែ<br>អាសាឍ ឆ្នាំជូត ទោស័ក<br>ព.ស. ២៥៦៤<br>ថ្ងៃទី ៩ ខែ កក្កដា គ.ស.<br>២០២០ |

# បទកុសលមាណវជាតក

## បុព្វនិទាន

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធក្មេងប្រុសម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ពហុស្សុតំ** *ដូច្នេះជាដើម ។*

## បច្ចុប្បន្ននិទាន

*បានឮមកថា ក្មេងប្រុសនោះជាកូនរបស់កុដុម្ពិកៈក្នុងនគរសាវត្ថី ជាអ្នកឈ្លាសវៃក្នុងការសង្កេតមើលស្នាមជើង ក្នុងពេលដែលខ្លួនមានអាយុត្រឹមតែ ៧ ឆ្នាំប៉ុណ្ណោះ ។ ក្នុងកាលនោះ ឪពុករបស់ក្មេងនោះគិតថានឹងសាកល្បងកូននេះ ទើបបានទៅផ្ទះមិត្រដែលក្មេងនោះមិនដឹង ។ ក្មេងនោះមិនបានសួររកទីទៅរបស់*

ឪពុកទេ ដើរទៅដោយសង្កេតមើលស្នាមជើងរបស់ឪពុក បានទៅឈរនៅក្នុងសម្នាក់ឪពុក ។

ថ្ងៃមួយ ឪពុកសួរក្មេងនោះថា កូនជាទីស្រឡាញ់ កាលឪពុកទៅ ក៏ទៅមិនបានឲ្យកូនដឹងទេ ប៉ុន្តែកូនដឹងទីទៅរបស់ឪពុកបានដោយរបៀបណា ? ក្មេងនោះឆ្លើយប្រាប់ថា បពិត្រឪពុក ខ្ញុំចំណាំស្នាមជើងរបស់ឪពុកបាន ខ្ញុំពូកែខាងពិនិត្យមើលស្នាមជើង ។ ពេលនោះ ឪពុករបស់គេត្រូវការនឹងសាកល្បងម្តងទៀត ពេលបរិភោគអាហារព្រឹកហើយ ចេញអំពីផ្ទះទៅកាន់ផ្ទះអ្នកដែលស្និទ្ធស្នាលគ្នា ដែលនៅជាប់ៗ គ្នា ហើយចេញអំពីផ្ទះនោះ ទៅកាន់ផ្ទះទី ៣ ចេញអំពីផ្ទះទី ៣ មកកាន់ផ្ទះខ្លួនវិញ ហើយចេញអំពីក្លោងទ្វារផ្ទះរបស់ខ្លួន ទៅកាន់ក្លោងទ្វារក្រុងទិសឧត្តរ

# បទកុសលមាណវជាតក

ចេញអំពីក្លោងទ្វារនោះ ដើរវាងក្រុងទៅខាងត្បូង ទៅដល់ព្រះវិហារជេតពន ថ្វាយបង្គំព្រះសាស្ដាហើយអង្គុយស្ដាប់ធម៌ ។ ក្មេងនោះសួរអ្នកស្រុកថា ឪពុកខ្ញុំទៅណា ? កាលបានទទួលពាក្យឆ្លើយតបថា មិនដឹងក៏បានពិនិត្យស្នាមជើងរបស់ឪពុក តាំងពីផ្ទះរបស់អ្នកដែលស្និទ្ធស្នាល ដែលនៅជាប់ៗគ្នា ទៅតាមផ្លូវដែលឪពុកទៅនោះឯង រហូតដល់ព្រះវិហារជេតពន ថ្វាយបង្គំព្រះសម្មាសម្ពុទ្ធហើយ ទៅឈរជិតឪពុក កាលឪពុករបស់គេសួរថា នែកូន កូនឯងដឹងថា ពុកមកទីនេះឬ ។ គេឆ្លើយថា ខ្ញុំចំណាំស្នាមជើងរបស់ពុកបាន ទើបបានមកកាន់ទីនេះ ដោយការពិនិត្យមើលស្នាមជើង ។ ព្រះសាស្ដាត្រាស់សួរថា ម្នាលឧបាសកអ្នកនិយាយអ្វី ? កាលកុដុម្ពិកៈក្រាបទូលថា បពិត្រ

# បទកុសលមាណវជាតក

ព្រះអង្គដ៏ចម្រើន ក្មេងម្នាក់នេះឆ្លាតក្នុងការពិនិត្យមើលស្នាមជើង ខ្ញុំព្រះអង្គចង់សាកល្បងក្មេងនេះ កាលមិនឃើញខ្ញុំព្រះអង្គក្នុងផ្ទះ បានមកដោយការពិនិត្យមើលស្នាមជើងរបស់ខ្ញុំព្រះអង្គ, ទើបព្រះសាស្តាត្រាស់ថា ម្នាលឧបាសក ការចំណាំស្នាមជើងលើផែនដីបាននេះ មិនគួរឲ្យអស្ចារ្យទេ បណ្ឌិតពីមុនៗ ចំណាំស្នាមជើងក្នុងអាកាសបាន ។ កុដុម្ពិកៈនោះក្រាបទូលអារាធនាឲ្យទ្រង់ត្រាស់រឿងរ៉ាវ ទើបទ្រង់នាំរឿងអតីតមកសម្តែងដូចតទៅនេះ

## អតីតនិទាន

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី, ព្រះអគ្គមហេសីរបស់ព្រះអង្គប្រព្រឹត្តក្រៅចិត្ត (ក្បត់ព្រះអង្គ) កាលព្រះរាជាត្រាស់សួរ ក៏ស្បថថា ប្រសិនបើខ្ញុំម្ចាស់ក្បត់ព្រះ

# បទកុសលមាណវជាតក

អង្គ សូមឲ្យខ្ញុំម្ចាស់កើតជាយក្ខិនីមានមុខដូចសេះចុះ។ ក្រោយអំពីនោះមក ព្រះនាងក៏អស់ព្រះជន្មកើតជាយក្ខិនីមានមុខដូចសេះ នៅក្នុងគុហាមួយ ចាប់មនុស្សដែលសញ្ចរទៅមកក្នុងព្រៃធំស៊ីជាអាហារ ។ បានឮថានាងយក្ខិនីនោះទៅបម្រើស្តេចវេស្សវ័ណ ៣ ឆ្នាំ បានទទួលពរ ឲ្យចាប់មនុស្សស៊ីបានក្នុងទីត្រាច់ទៅ ៣០ យោជន៍ អំពីចំណែកបណ្តោយនិងទទឹង៥ យោជន៍ ។

ថ្ងៃមួយ ព្រាហ្មណ៍រូបស្អាតម្នាក់ ជាអ្នកស្តុកស្តម្ភមានទ្រព្យច្រើន ចោមរោមដោយមនុស្សជាច្រើន ធ្វើដំណើរទៅតាមផ្លូវនោះ ។ នាងយក្ខិនីឃើញដូច្នោះ ក៏មានសេចក្តីត្រេកអរ រត់ទៅ, ពួកមនុស្សដែលជាបរិវារនាំគ្នារត់គេចបាត់អស់ ។ នាងយក្ខិនីរត់លឿនដូចខ្យល់ចាប់ព្រាហ្មណ៍បានហើយឲ្យដេកលើខ្នង នាំទៅ

គុហា កាលបានប៉ះសម្ផស្សរបស់បុរសនោះភ្លាម ក៏កើតស្រឡាញ់ព្រាហ្មណ៍នោះ ដោយកិលេស ទើបមិនបានទំពាស៊ី យកទុកធ្វើជាស្វាមីរបស់ខ្លួន ។ យក្ខិនីនិងបុរសនោះក៏រស់នៅជាមួយគ្នាដោយសមគ្គសំវាស នាងយក្ខិនីទៅចាប់មនុស្សយកសម្លៀកបំពាក់ អង្ករ និងប្រេងជាដើមមកផ្សំជាអាហារមានរសដ៏ប្រណីតផ្សេងៗ ឲ្យស្វាមី ខ្លួនឯងស៊ីសាច់មនុស្ស ។ វេលាដែលនាងទៅទីណា បានយកផ្ទាំងថ្មធំបិទទ្វារគុហាសិន ហើយទើបទៅ ព្រោះខ្លាចព្រាហ្មណ៍រត់ចោលខ្លួន ។ កាលព្រាហ្មណ៍និងនាងយក្ខិនីនៅជាមួយគ្នាយ៉ាងសុខសប្បាយដូច្នេះ ព្រះពោធិសត្វក៏ចុតិអំពីទីដែលព្រះអង្គកើត មកបដិសន្ធិក្នុងគភ៌របស់នាងយក្ខិនីនោះ ព្រោះអាស្រ័យព្រាហ្មណ៍ ។ លុះកន្លងទៅបាន ១០

ខែ នាងយក្ខិនីក៏ប្រសូតបុត្រ នាងមានសេចក្តី
ស្រឡាញ់បុត្រនិងព្រាហ្មណ៍ខ្លាំងណាស់ បានចិញ្ចឹម
មើលថែអ្នកទាំងពីរនោះយ៉ាងល្អ ។ ក្រោយមក កាល
បុត្រចម្រើនវ័យហើយ នាងយក្ខិនីបាននាំបុត្តចូលនៅ
ខាងក្នុងល្អាងជាមួយនឹងឪពុក ហើយបិទទ្វារល្អាង ។
ថ្ងៃមួយ ព្រះពោធិសត្វដឹងថា យក្ខិនីមាតាទៅហើយ
ទើបបានយកផ្ទាំងថ្មចេញ នាំឪពុកចេញទៅខាងក្រៅ។
នាងយក្ខិនីមកសួរថា អ្នកណាយកថ្មចេញ កាលព្រះ
ពោធិសត្វឆ្លើយតបថា ខ្ញុំយកចេញម៉ែ ខ្ញុំមិនអាចនឹង
អង្គុយក្នុងទីងងឹតបាន ។ នាងក៏មិនបានថាអ្វី ព្រោះ
ស្រឡាញ់កូន ។

ថ្ងៃមួយ ព្រះពោធិសត្វសួរឪពុកថា ហេតុដូច
ម្តេចមុខរបស់ម្តាយមិនដូចមុខឪពុក ។ ព្រាហ្មណ៍ជា

# បទកុសលមាណវជាតក

ឪពុកពោលថា កូនសម្លាញ់ ម្តាយរបស់កូនជាយក្ខិនី ស៊ីសាច់មនុស្ស យើងទាំងពីរនាក់ឪពុកនិងកូននេះជាមនុស្ស ។ ព្រះពោធិសត្វពោលថា ឪពុក បើដូច្នោះ យើងនឹងនៅទីនេះធ្វើអ្វី ? យើងទៅកាន់ដែនដីមនុស្សទៅ ។ ព្រាហ្មណ៍ជាឪពុកពោលថា កូនសម្លាញ់ ប្រសិនបើយើងរត់គេច ម៉ែរបស់កូនឯងនឹងសម្លាប់យើងទាំងពីរ ។ ព្រះពោធិសត្វនិយាយលួងលោមចិត្តឪពុកថា បពិត្រឪពុក សូមឪពុកកុំខ្លាច ខ្ញុំនឹងទទួលភារៈនាំឪពុកទៅឲ្យដល់ដែនដីរបស់មនុស្ស ។ លុះស្អែកឡើងកាលមាតាទៅហើយ បាននាំឪពុករត់គេច ។ នាងយក្ខិនីត្រឡប់មកវិញ មិនឃើញអ្នកទាំងពីរនោះ ក៏រត់ទៅយ៉ាងលឿនដូចខ្យល់ ចាប់អ្នកទាំង ២ បាន ហើយពោលថា បពិត្រព្រាហ្មណ៍ លោករត់គេចធ្វើអ្វី

លោកនៅទីនេះខ្វះខាតអ្វីឬ ? កាលព្រាហ្មណ៍ពោលថា អូនសម្លាញ់ អូនឯងកុំខឹងបងអី កូនរបស់អូននាំបងទៅទេ ។ នាងក៏មិនបានថាអ្វីកូនដែរ ព្រោះស្រឡាញ់កូនពេក លួងលោមអ្នកទាំងពីរនោះ ឲ្យស្រាលចិត្តហើយនាំទៅកាន់លំនៅរបស់ខ្លួន ។ នាងយក្ខិនីនាំអ្នកទាំងពីរ ដែលព្យាយាមរត់គេចទៅពីរបីថ្ងៃនោះ ឲ្យត្រឡប់មកវិញទៀត ។

ព្រះពោធិសត្វគិតថា ម៉ែរបស់យើងគង់មានទីដែលជាដែនកំណត់ទុក ធ្វើដូចម្តេចហ្ន៎ យើងនឹងសួរអំពីដែនដែលនៅក្នុងអាណាខេត្តរបស់គាត់ឲ្យបាន កាលសួរបាន យើងនឹងរត់គេចឲ្យផុតអំពីខេត្តដែននោះ ។ ថ្ងៃមួយ ព្រះពោធិសត្វឱបមាតារបស់ព្រះអង្គដែលអង្គុយក្នុងទីមួយ ហើយពោលថា ម៉ែ ធម្មតា

របស់ដែលជារបស់មាតាតែងធ្លាក់មកដល់ពួកកូនៗ សូមម៉ែមេត្តាប្រាប់ព្រំដែនកំណត់ដែនដីដែលជារបស់ម៉ែដល់ខ្ញុំ ។ នាងយក្ខិនីប្រាប់ទីបណ្តោយ ៣០ យោជន៍ ទទឹង ៥ យោជន៍ មានភ្នំជាដើម ជាគ្រឿងសម្គាល់ក្នុងទិសទាំងពួងដល់បុត្រ ហើយពោលថា កូនសម្លាញ់ កូនឯងចូរចំណាំនូវទីដែលមានប្រមាណប៉ុណ្ណេះចុះ ។ លុះកន្លងទៅបាន ២-៣ ថ្ងៃ កាលមាតាទៅព្រៃហើយ ព្រះពោធិសត្វបានលីឪពុករត់ទៅយ៉ាងលឿនដូចខ្យល់តាមសញ្ញាដែលមាតាបានប្រាប់ ទៅដល់ឆ្នេរស្ទឹងដែលជាដែនកំណត់ ។ នាងយក្ខិនីត្រឡប់មក កាលមិនឃើញព្រះពោធិសត្វនិងព្រាហ្មណ៍ដែលជាប្តី ក៏ចេញតាមទៅរក ។ ព្រះពោធិសត្វនាំឪពុកមកដល់កណ្តាលស្ទឹង នាងយក្ខិនីទៅឈរនៅលើមាត់ស្ទឹង

# បទកុសលមាណវជាតក

ដឹងថា អ្នកទាំង ២ កន្ទង់ហួសព្រំដែនរបស់ខ្លួនទៅ ហើយ ក៏ឈរនៅទីនោះអង្វរបុត្រនិងស្វាមីថា កូនសម្លាញ់ កូនចូរនាំឪពុកត្រឡប់មក ម៉ែមានកំហុសអ្វីឬ សូមត្រឡប់មកវិញ ប្តីសម្លាញ់ ។ ពេលនោះ ព្រាហ្មណ៍បានធ្ងង់ផុតពីស្មឹង ។ នាងយក្ខិនីអង្វរកូនថា កូនសម្លាញ់ កូនកុំធ្វើយ៉ាងនេះឡើយ កូនចូរត្រឡប់មកវិញចុះ ។ ព្រះពោធិសត្វពោលថា ម៉ែ ខ្ញុំនិងពុកជាមនុស្ស ម៉ែជាយក្ខិនី ខ្ញុំមិនអាចនៅក្នុងសម្នាក់ម៉ែរហូតអស់កាលជានិច្ចបានទេ ដូច្នេះ ខ្ញុំនិងពុកនឹងមិនត្រឡប់ទេ ។ នាងយក្ខិនីសួរថា កូនសម្លាញ់ កូនឯងនឹងមិនត្រឡប់ពិតឬ ? ព្រះពោធិសត្វឆ្លើយថា ពិតមែនហើយម៉ែ កូននឹងមិនត្រឡប់ទេ ។ នាងយក្ខិនីពោលថា កូនសម្លាញ់ បើកូនមិនត្រឡប់ក៏ណ្ហើយចុះ

ឈ្មោះថា ជីវិតក្នុងមនុស្សលោកនេះជារបស់លំបាក អ្នកដែលមិនចេះសិល្បវិទ្យា មិនអាចញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅបានឡើយ ម៉ែចេះវិជ្ជាម្យ៉ាងឈ្មោះ **ចិន្តា-មណី** ដោយអានុភាពនៃវិជ្ជានោះ អាចនឹងតាមស្នាមជើងរបស់អ្នកដែលបាត់ទៅហើយអស់ ១២ ឆ្នាំ ជាទីបំផុត វិជ្ជានេះនឹងជាគ្រឿងចិញ្ចឹមជីវិតកូន កូនសម្លាញ់ កូនចូររៀនមន្តដែលកាត់ថ្ងៃមិនបាននេះចុះ ថាដូច្នេះហើយ ទាំងដែលត្រូវសេចក្ដីទុក្ខបែបនោះគ្របសង្កត់នោះឯង នាងក៏បានបង្រៀនមន្តឲ្យ ដោយសេចក្ដីស្រឡាញ់កូន ។ ព្រះពោធិសត្វឈរនៅក្នុងស្ទឹងនោះឯង ថ្វាយបង្គំមាតាហើយ ប្រណមដៃរៀនមន្ត លុះរៀនយកបានហើយ បានថ្វាយបង្គំមាតាម្ដងទៀត ហើយពោលថា ម៉ែ សូមម៉ែទៅចុះ ។ នាងយក្ខិនីពោល

# **បទកុសលមាឈាវជាតក**

*កូនសម្លាញ់ កាលកូននិងពុករបស់កូនមិនត្រឡប់ ជីវិតរបស់ម៉ែក៏នឹងមិនមាន ហើយបានពោលគាថាថា*

ឯហិ បុត្ត និវត្តស្សុ,
មា អជាចំ ករោហិ មេ;
អជ្ជ បុត្តំ អបស្សន្តី,
យក្ខិនី មរណំ គតា។

***កូនសម្លាញ់ កូនចូរមករកម៉ែ ចូរត្រឡប់ទៅនៅជាមួយចុះ កុំធ្វើឲ្យម៉ែមិនមានទីពឹងឡើយ កាលម៉ែមិនបានឃើញកូននឹងស្លាប់ក្នុងថ្ងៃនេះឯង ។***

*លុះពោលហើយ នាងយក្ខិនីបានទះទ្រូងរបស់ខ្លួន ។ ភ្លាមនោះ បេះដូងរបស់នាងបានបែក ព្រោះសេចក្តីសោកដល់បុត្រ ។ នាងស្លាប់នៅទីនោះឯង ។ ពេលនោះ ព្រះពោធិសត្វដឹងថា មាតាស្លាប់ ក៏ហៅឪពុក ទៅជិតមាតា ហើយធ្វើជើងថ្ករបូជាសពមាតា*

រួចហើយបានបូជាដោយផ្កាឈើផ្សេងៗ យំសោក ខ្សឹកខ្សួលហើយ នាំឪពុកទៅកាន់នគរពារាណសី ឈរនៅនឹងក្លោងទ្វារព្រះរាជនិវេសន៍ ឲ្យទៅក្រាបទូល ព្រះបាទពារាណសីថា មានមាណពដែលពូកែខាង ពិនិត្យស្នាមជើងមកឈរនៅនឹងក្លោងទ្វារ សូមចូល គាល់ កាលបានទទួលការអនុញ្ញាតថា បើដូច្នោះចូល មកចុះ លោកបានចូលទៅថ្វាយបង្គំព្រះបាទពារា-ណសី កាលព្រះរាជាត្រាស់សួរថា នៃមាណព អ្នក ចេះសិល្បវិជ្ជាអ្វី ។ លោកក្រាបទូលថា បពិត្រមហា-រាជ ទូលព្រះបង្គំចេះវិជ្ជាដែលអាចទៅតាមស្នាមជើង ហើយ ចាប់មនុស្សដែលលួចរបស់ទៅហើយរហូត ១២ ឆ្នាំបាន ។ ព្រះបាទពារាណសីត្រាស់ថា បើ ដូច្នោះ អ្នកចូរទទួលរាជការនៅជាមួយយើង ។ ព្រះ

ពោធិសត្វក្រាបទូលថា កាលទូលព្រះបង្គំបានទទួលព្រះរាជទានទ្រព្យមួយថ្ងៃមួយពាន់ ទើបទូលព្រះបង្គំទទួលរាជការ ។ ព្រះបាទពារាណសីត្រាស់ថា ប្រពៃហើយ មាណព អ្នកចូរទទួលរាជការចុះ ។ ព្រះបាទពារាណសីបញ្ជាឲ្យព្រះរាជទានទ្រព្យមួយថ្ងៃមួយពាន់ ។

ថ្ងៃមួយ បុរោហិតក្រាបទូលព្រះបាទពារាណសីថា បពិត្រមហារាជ យើងទាំងឡាយមិនដឹងថា មាណពនោះចេះមន្តវិជ្ជានោះ ឬក៏មិនចេះទេ ព្រោះគេមិនទាន់បានធ្វើកម្មយ៉ាងណាមួយ ដោយអានុភាពនៃមន្តវិជ្ជានោះ គួរតែសាកល្បងមាណពនោះមើល៍ ។ ព្រះរាជាទ្រង់ទទួលថា ប្រពៃហើយ ។ ព្រះរាជានិងបុរោហិតទាំងពីរនាក់ក៏ឲ្យសញ្ញា ដល់អ្នករក្សារតនៈ

ហើយកាន់យករតនៈសំខាន់ៗ ចុះអំពីប្រាសាទ ដើរ
ព័ទ្ធជុំវិញចន្លោះព្រះរាជនិវេសន៍ ៣ ជុំ ហើយគង់លើ
ជណ្ដើរ ចុះមកខាងក្រៅចុងកំផែង ចូលទៅកាន់
សាលាវិនិច្ឆ័យ អង្គុយក្នុងទីនោះ ហើយដើរត្រឡប់មក
កាន់ជណ្ដើរ ចុះទៅក្នុងព្រះរាជនិវេសន៍តាមចុងកំផែង
ដើរទៅកាន់មាត់ស្រះបោក្ខរណី ៣ ជុំ ហើយចុះទៅ
ដាក់វត្ថុក្នុងស្រះបោក្ខរណី ហើយទើបឡើងកាន់
ប្រាសាទ ។ ថ្ងៃស្អែក បានកើតកោលាហលថា ពួក
ចោរលួចយករតនៈអំពីព្រះរាជនិវេសន៍ ព្រះរាជាធ្វើ
ដូចជាទ្រង់មិនជ្រាប ទ្រង់បញ្ជាឲ្យហៅព្រះពោធិសត្វ
មកហើយ ត្រាស់ថា នែមាណព រតនៈមានតម្លៃច្រើន
ត្រូវចោរលួចយកទៅ ដូច្នេះអ្នកត្រូវតែតាមរករតនៈ
នោះមកឲ្យបាន ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រ

មហារាជ របស់ដែលចោរលួចយកទៅអស់កាលយូរ ដល់ ១២ ឆ្នាំ ទូលព្រះបង្គំនៅអាចតាមស្នាមជើងចោរ នាំរបស់មកបានដោយមិនមានការសង្ស័យ របស់ដែលត្រូវចោរលួចយកទៅ កាលយប់មិញ ទូលព្រះបង្គំនឹងអាចនាំមក ក្នុងថ្ងៃនេះឯង សូមព្រះអង្គកុំព្រួយព្រះទ័យឡើយ ។ ព្រះរាជាទ្រង់បញ្ជាថា នែមាណព បើដូច្នោះ អ្នកចូរទៅនាំមកចុះ ។ ព្រះពោធិសត្វក្រាបទូលថា ប្រពៃហើយព្រះអង្គ ហើយឈរនៅក្នុងផ្ទៃព្រះរោង ថ្វាយបង្គំមាតា រួចរាយមន្តចិន្តាមណី ហើយក្រាបទូលថា ស្នាមជើងរបស់ចោរពីរនាក់ ប្រាកដហើយព្រះអង្គ លោកដើរតាមស្នាមជើងរបស់ព្រះរាជានិងបុរោហិត ចូលទៅកាន់បន្ទប់ដ៏មានសិរី ចេញអំពីបន្ទប់នោះ ចុះអំពីប្រាសាទ ដើរជុំវិញ

ចន្ទោះព្រះរាជនិវេសន៍ ៣ ជុំ ហើយទៅជិតកំផែង ដើរ
តាមស្នាមជើងនោះ ឈរនៅលើកំផែង ហើយពោល
ថា បពិត្រមហារាជ ផុតអំពីកំផែងនៅទីនេះ តអំពីនេះ
ទៅ ស្នាមជើងប្រាកដនៅលើអាកាស សូមព្រះអង្គ
ទ្រង់ព្រះរាជទានជណ្ដើរហើយឲ្យដាក់ជណ្ដើរចុះតាម
កំផែងដើរទៅកាន់សាលាវិនិច្ឆ័យតាមស្នាមជើងនោះ
ហើយដើរត្រឡប់មកកាន់ព្រះរាជនិវេសន៍វិញ ឲ្យដាក់
ជណ្ដើរហើយ ចុះតាមចុងកំផែងទៅកាន់ស្រះ
បោក្ខរណី ដើរប្រទក្សិណស្រះបោក្ខរណី ៣ ជុំ ហើយ
ក្រាបទូលថា បពិត្រមហារាជ ពួកចោរចុះស្រះ
បោក្ខរណីនេះ ហើយចុះទៅនាំរបស់នោះមក ដូចនាំ
យករបស់ដែលខ្លួនទុកដាក់ខ្លួនឯង មកថ្វាយព្រះបាទ
ពារាណសីហើយក្រាបទូលថា បពិត្រមហារាជ ចោរ

២ នាក់នេះ ជាមហាចោរដែលព្រះអង្គទ្រង់ស្គាល់ច្បាស់ ទើបបានឡើងកាន់ព្រះរាជនិវេសន៍តាមផ្លូវនេះ។ មហាជននាំគ្នាត្រេកអររីករាយ ម្នាក់ៗ ទះដៃសរសើរ ពួកខ្លះក៏លើកសំពត់ឡើងគ្រវី ។

ព្រះរាជាព្រះតម្រិះថា មាណពនេះដើរទៅដោយការសង្កេតស្នាមជើង ប្រហែលជាដឹងតែទីដែលពួកចោរដាក់ទុកភណ្ឌៈប៉ុណ្ណោះ ប៉ុន្តែមិនអាចចាប់ចោរបាន ។ ព្រះរាជាក៏បានត្រាស់ទៅកាន់ព្រះពោធិសត្វថា អ្នកនាំរបស់ដែលពួកចោរលួចយកទៅមកឲ្យយើងបាន ប៉ុន្តែមិនអាចចាប់ពួកចោរនាំមក ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ពួកចោរនៅទីនេះឯង មិនបាននៅទីឆ្ងាយទេ ។ ព្រះរាជាត្រាស់សួរថា អ្នកណាជាចោរ អ្នកណាជាចោរ ។ ព្រះ

ពោធិសត្វក្រាបទូលថា បពិត្រមហារាជ អ្នកណាតែង ចង់បាន អ្នកនោះឯងជាចោរ កាលបានវត្ថុរបស់ព្រះ អង្គមកហើយ នឹងមានប្រយោជន៍អ្វីទៀត ចំពោះពួក ចោរនោះ សូមព្រះអង្គកុំសួរដល់ចោរឡើយ ។ ព្រះ រាជាទ្រង់ត្រាស់ថា ម្នាលមាណព យើងឲ្យទ្រព្យដល់ អ្នកមួយថ្ងៃមួយពាន់រាល់ថ្ងៃ អ្នកចូរចាប់ពួកចោរមក ឲ្យយើង ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហា-រាជ ទ្រព្យដែលបាត់ទៅ ព្រះអង្គក៏បានមកហើយ ព្រះ អង្គត្រូវការពួកចោរនោះធ្វើអ្វីទៀត ។ ព្រះរាជាទ្រង់ ត្រាស់ថា ម្នាលមាណព យើងបានពួកចោរសមគួរ ជាងបានទ្រព្យ ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រ ព្រះសម្មតិទេព បើដូច្នោះ ទូលព្រះបង្គំនឹងមិនក្រាប ទូលព្រះអង្គថា មនុស្សទាំងនេះជាចោរ ប៉ុន្តែនឹងនាំ

# បទកុសលមាណវជាតក

រឿងដែលមានហើយក្នុងអតីត មកក្រាបទូលព្រះអង្គ បើព្រះអង្គទ្រង់ព្រះប្រាជ្ញាញាណ នឹងទ្រង់ជ្រាបហេតុនោះ លុះក្រាបទូលដូច្នេះហើយ បាននាំយករឿងអតីតមកសម្ដែងដូចតទៅនេះ ៖

ក្នុងអតីតកាល មានអ្នករបាំម្នាក់ឈ្មោះ បាដលិ រស់នៅក្នុងស្រុកក្បែរមាត់ស្ទឹង មិនឆ្ងាយអំពីព្រះនគរពារាណសីប៉ុន្មានទេ ។ ថ្ងៃមួយ មានមហោស្រព អ្នករបាំនោះនាំភរិយាទៅនគរពារាណសី រាំច្រៀងបានទ្រព្យ លុះមហោស្រពចប់ហើយ បានទិញសុរាអាហារជាច្រើន ហើយធ្វើដំណើរត្រឡប់មកផ្ទះរបស់ខ្លួនវិញ ដល់ស្ទឹងមួយឃើញទឹកថ្មីកំពុងហូរមក ក៏អង្គុយបរិភោគអាហារ ផឹកសុរាស្រវឹងរហូតមិនដឹងកម្លាំងរបស់ខ្លួន យកពិណធំចងកហើយ ចុះទឹកចាប់ដៃ

ភរិយា ហើយនិយាយថា យើងទៅជាមួយគ្នា ពោល ហើយ ចុះហែលឆ្លងស្ទឹងទៅ ។ ទឹកបានចូលតាមប្រហោងពិណ ពេលនោះ ពិណនោះបានប្រទាញគេឲ្យលិចចូលទៅក្នុងទឹក ។ ចំណែកភរិយារបស់គេដឹងថា ស្វាមីរបស់ខ្លួនលិចទឹក ក៏រលាស់ដៃចេញអំពីគេ ហើយឡើងទៅឈរនៅលើច្រាំង ។ មាណពនោះលិចទឹកមុជងើបៗ ផឹកទឹករហូតពេញពោះ ។ ពេលនោះ ភរិយារបស់គាត់ក៏គិតថា ស្វាមីរបស់យើងនឹងស្លាប់ក្នុងពេលនេះ យើងនឹងសូមបទចម្រៀងឲ្យបានមួយបទ យកទុកសម្រាប់ច្រៀងក្នុងកណ្ដាលបរិស័ទចិញ្ចឹមជីវិត លុះគិតដូច្នេះហើយ ក៏បានពោលថា បងអើយ បងនឹងលិចក្នុងទឹក សូមបងឲ្យបទចម្រៀងមួយបទ

ដល់អូន អូននឹងចិញ្ចឹមជីវិតដោយបទចម្រៀង នោះ ដូច្នេះហើយទើបពោលគាថាថា

ពហុស្សុតំ ចិត្តកថី
គង្គា វហតិ ចាដលី
វុយ្ហមានកា ភទ្ទន្តេ
ឯកំ មេ ទេហិ គាថកំ ។

ទឹកទន្លេគង្គាកួចយកទៅ នូវបុរសឈ្មោះ បាដលិ ជាអ្នក ចេះដឹងច្រើន ពោលនូវពាក្យដ៏វិចិត្រ នៃអ្នកដ៏ចម្រើន ដែល ទឹកកួចយកទៅ សូមអ្នកឲ្យនូវចម្រៀងយ៉ាងខ្លីមួយដល់ខ្ញុំ ។

ពេលនោះ បាដលិបានពោលទៅកាន់ភរិយាថា អូនសម្លាញ់ បងនឹងឲ្យបទចម្រៀងដល់អូនឯងដូចម្ដេចបាន ពីព្រោះទឹកដែលជាទីពឹងអាស្រ័យរបស់

មហាជននោះ ពេលនេះ កំពុងនឹងសម្លាប់បង់ហើយ លុះពោលដូច្នេះហើយ ទើបពោលគាថា ថា

យេន សិញ្ចន្តិ ទុក្ខិតំ
យេន សិញ្ចន្តិ អាតុរំ
តស្ស មជ្ឈេ មរិស្សាមិ
ជាតំ សរណតោ ភយំ ។

ពួកជនតែងស្រោចនូវបុគ្គលមានទុក្ខ ដោយទឹកណា តែង ស្រោចនូវបុគ្គលដែលមានសេចក្តីក្រវល់ក្រវាយដោយទឹកណា យើងគង់នឹងស្លាប់ ក្នុងកណ្តាលទឹកនោះ ភ័យកើតមកអំពីវត្ថុជាទីពឹងហើយ ។

ព្រះពោធិសត្វសម្តែងគាថានេះហើយ ក្រាបទូលថា បពិត្រមហារាជ ទឹកជាទីពឹងរបស់មហាជនយ៉ាងណា សូម្បីព្រះរាជាទាំងឡាយ ក៏ជាទីពឹងរបស់មហាជនដូច្នោះដែរ កាលភ័យអំពីសម្នាក់ព្រះរាជា

# បទកុសលមាណវជាតក

ទាំងនោះហើយ អ្នកណានឹងការពារភ័យនោះបាន លុះពោលដូច្នេះហើយ ក្រាបទូលទៀតថា បពិត្រមហារាជ រឿងចោរលួចព្រះរាជទ្រព្យនេះជារឿងអាថ៌កំបាំង ប៉ុន្តែទូលព្រះបង្គំក្រាបទូល ដូចដែលបណ្ឌិតនឹងដឹងបាន សូមព្រះអង្គទ្រង់ជ្រាបចុះ។ ព្រះរាជាទ្រង់ត្រាស់ថា ម្នាលមាណព យើងនឹងដឹងរឿងអាថ៌កំបាំងបែបនេះបានយ៉ាងណា អ្នកចូរចាប់ចោរមកឲ្យយើង ។ ពេលនោះ ព្រះបរមពោធិសត្វបានក្រាបទូលព្រះរាជាថា បពិត្រមហារាជ បើដូច្នោះ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់នូវរឿងនេះហើយ នឹងទ្រង់ជ្រាប ហើយនាំយករឿងដទៃមកតំណាលថ្វាយមួយរឿងទៀតដូចតទៅនេះ ៖

# បទកុសលមាណវជាតក

បពិត្រព្រះសម្មតិទេព ក្នុងកាលកន្លងទៅហើយ ឯស្រុកមួយជិតក្លោងទ្វារនគរពារាណសីនេះ មាន ស្ទូនថ្នាំងម្នាក់ កាលនឹងនាំដីស្អិតមកដើម្បីធ្វើ ភាជនៈ បានជីកយកដីស្អិតក្នុងទីកន្លែងមួយជានិច្ច ដូច្នេះកន្លែងនោះ បានក្លាយទៅជារណ្ដៅមួយដ៏ធំខាង ក្នុងញកភ្នំ ។ ថ្ងៃមួយ នៅពេលដែលជាងថ្នាំងនោះ កំពុងតែជីកយកដីស្អិតដុំពពកខ្មៅមួយដុំធំ បានតាំង ឡើងក្នុងវេលាដែលមិនមែនជារដូវភ្លៀង ញាំងភ្លៀង ឲ្យបង្អុរចុះមកមួយមេធំ ទឹកហូរមកជន់លិចរណ្ដៅ បាក់ដុំដីសង្កត់ក្បាលនាយស្ទូនថ្នាំងនោះបែក នាយ ស្ទូនថ្នាំងខ្សឹកខ្សួល ពោលគាថា ថា

យត្ថ ពីជានិ រូហន្តិ

សត្តា យត្ថ បតិដ្ឋិតា

# បទកុសលមាណវជាតក

សា មេ សីសំ និបីឡេតិ

ជាតំ សរណតោ ភយំ ។

ពូជទាំងឡាយតែងដុះឡើងលើផែនដីណា ពួកសត្វឋិត នៅលើផែនដីណា ផែនដីនោះ បៀតបៀនទូវក្បាលអញ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

ព្រះបរមពោធិសត្វទូលតទៅទៀត បពិត្រមហារាជ ផែនដីដ៏ធំដែលជាទីពឹងអាស្រ័យរបស់សត្វលោក បានបំបែកក្បាលរបស់នាយស្ទូនឆ្នាំង យ៉ាងណា កាលព្រះរាជាដែលជាធំលើនរជន ជាទីពឹងអាស្រ័យនៃសត្វលោកទាំងអស់ ស្មើដោយផែនដីមកធ្វើចោរកម្មយ៉ាងនេះ អ្នកណាទៅនឹងការពារបាន បពិត្រមហារាជ ព្រះអង្គអាចទ្រង់ជ្រាបចោរដែលទូលបង្គំក្រាបទូលឲ្យបិទបាំងទុកបាន ដោយឧបាយយ៉ាង

នេះ ។ ព្រះបាទពារាណសីត្រាស់ថា ម្នាលមាណព ហេតុដែលយើងនឹងបិទបាំងនោះ មិនមាន អ្នកចូរទៅចាប់ចោរឲ្យយើង ដោយចង្អុលថា អ្នកនេះឯងជាចោរ ដូច្នេះ ។ ព្រះពោធិសត្វកាលនឹងរក្សាកិត្តិគុណព្រះរាជា ទើបមិនបានពោលថា ព្រះអង្គជាចោរ បាននាំឧទាហរណ៍មកក្រាបទូលថ្វាយមួយរឿងទៀតថា

បពិត្រមហារាជ ក្នុងកាលមុន កាលភ្លើងឆេះផ្ទះរបស់បុរសម្នាក់ ក្នុងព្រះនគរនេះឯង គេប្រើមនុស្សម្នាក់ថា អ្នកចូរ ចូលទៅខាងក្នុង ជញ្ជូនរបស់របរចេញ។ កាលបុរសនោះកំពុងចូលទៅជញ្ជូនទ្រព្យ ទ្វារផ្ទះក៏បិទ ។ បុរសនោះងងឹតភ្នែក ព្រោះត្រូវផ្សែងចូលភ្នែក រកផ្លូវចេញមិនឃើញ កើតទុក្ខឡើងព្រោះកម្ដៅ ឈរយំរៀបរាប់ខាងក្នុង រួចហើយទើបពោលគាថាថា

## បទកុសលមាណវជាតក

យេន ភត្តានិ បច្ចន្តិ
សីតំ យេន វិហញ្ញតិ
សោ មំ ឌហតិ ភត្តានិ
ជាតំ សរណតោ ភយំ ។

*ពួកជនគេចម្អិនបាយ ដោយភ្លើងណា គេកម្ចាត់បង់នូវរងា ដោយភ្លើងណា ភ្លើងនោះឆេះនូវកាយរបស់អញ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។*

*ព្រះពោធិសត្វក្រាបទូលតទៅថា បពិត្រមហារាជ មនុស្សម្នាក់ជាទីពឹងរបស់មហាជន ដូចជាភ្លើងជាទីពឹងអាស្រ័យដូច្នោះ បានលួចទ្រព្យគឺរតនៈទៅ សូមព្រះអង្គកុំទ្រង់សួរដល់ចោរនឹងទូលព្រះបង្គំអី ។ ព្រះរាជាត្រាស់ថា ម្នាលមាណព អ្នកចូរប្រាប់ចោរឲ្យយើងបានដឹង ។ ព្រះពោធិសត្វមិនបានក្រាបទូលព្រះរាជា*

# បទកុសលមាណវជាតក

ថា ព្រះអង្គជាចោរទេ បាននាំឧទាហរណ៍មកថ្វាយមួយរឿងទៀតថា ៖

បពិត្រព្រះអង្គ ក្នុងកាលមុនបុរសម្នាក់ នៅក្នុងព្រះនគរនេះឯង បរិភោគអាហារច្រើនពេក អាហារមិនរលាយ ដល់នូវទុក្ខវេទនាដ៏ខ្លាំងក្លា សោកសៅពោលគាថាថា

យេន កុត្តេន យាបេន្តិ
បុថូ ព្រាហ្មណខត្តិយា
សោ មំ កុត្តោ ព្យាធេតិ
ជា តំ សរណតោ ភយំ ។

ពួកព្រាហ្មណ៍និងក្សត្រិយ៍ ជាច្រើនតែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្តណា ភត្តនោះ ដែល

***អាត្មាអញ បរិភោគហើយនោះ សម្លាប់នូវអញ ភ័យកើតអំពីវត្ថុជា ទីពឹងហើយ ។***

*ព្រះពោធិសត្វក្រាបទូលតទៅថា បពិត្រមហារាជ បុគ្គលម្នាក់ជាទីពឹងរបស់មហាជន ប្រៀបដូចបាយដូច្នោះ ព្រះអង្គបានបាត់រតនៈ ឥឡូវនេះបានរតនៈនោះមកវិញហើយ ព្រះអង្គសួរដល់ចោរនោះធ្វើអ្វីទៀត ។ ព្រះរាជាត្រាស់ថា ម្នាលមាណព កាលអ្នកអាច ក៏ចូរនាំចោរនោះមកឲ្យយើង ។ ព្រះពោធិសត្វបាននាំឧទាហរណ៍មកក្រាបទូលមួយរឿងទៀតថា*

*បពិត្រមហារាជ ក្នុងកាលកន្លងទៅហើយ ខ្យល់បានកើតឡើង បក់ប្រហាររាងកាយរបស់បុគ្គលម្នាក់នៅក្នុងនគរនេះឯង បុគ្គលនោះ សោកខ្សឹកខ្សួលពោលគាថា ថា*

# បទកុសលមាណវជាតក

កិម្ហានំ បច្ឆិមេ មាសេ
វាតមិច្ឆន្តិ បណ្ឌិតា
សោ មំ ភញ្ជតិ កត្តានិ
ជាតំ សរណតោ ភយំ ។

ពួកអ្នកប្រាជ្ញ តែងប្រាថ្នាខ្យល់ ក្នុងខែជាទីបំផុតនៃគិម្ហរដូវ ( ឥឡូវ ) ខ្យល់នោះ កាច់បំបាក់ខ្លួនខ្ញុំ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

ព្រះពោធិសត្វក្រាបទូលតទៅថា បពិត្រមហារាជ ភ័យកើតឡើងអំពីទីពឹងដោយប្រការដូច្នេះ សូមព្រះអង្គទ្រង់ជ្រាបរឿងនេះចុះ ។ ព្រះរាជាត្រាស់ថា ម្នាលមាណព អ្នកចូរចាប់ចោរមកចុះ ។ ដើម្បីនឹងឲ្យព្រះរាជាទ្រង់ជ្រាប ព្រះពោធិសត្វនាំឧទាហរណ៍ មកក្រាបទូលមួយរឿងទៀតថា ៖

# បទកុសលមាណវជាតក

បពិត្រមហារាជ ក្នុងអតីតកាលក្នុងហិមវន្ត-ប្រទេស មានដើមឈើមួយដើមធំបរិបូណ៌ដោយមែកនិងប្រគាប ជាលំនៅរបស់បក្សីទាំងឡាយច្រើនពាន់ មែកពីរនៃដើមឈើនោះត្រដុសគ្នា រហូតដល់មានផ្សែងកើតឡើង បណ្ដាលឲ្យភ្លើងឆេះឡើង បក្សីដែលជាប្រធានឃើញដូច្នោះ ទើបពោលគាថា ថា

យំ និស្សិតា ជគតិរុហំ
ស្វាយំ អគ្គឹ បមុញ្ចតិ
ទិសា ភជថ វក្កង្គា
ជាតំ សរណតោ ភយំ ។

ពួកបក្សី តែងអាស្រ័យដើមឈើណា ដើមឈើនោះ បញ្ចេញនូវភ្លើង បក្សីទាំងឡាយ ចូរគប់នូវទិសទាំងឡាយផ្សេងៗ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

# បទកុសលមាណវជាតក

ព្រះពោធិសត្វក្រាបទូលតទៅថា បពិត្រមហា-
រាជ ដើមឈើដែលជាទីពឹងរបស់បក្សីទាំងឡាយ
យ៉ាងណា ព្រះរាជាក៏ជាទីពឹងរបស់មហាជនដូច្នោះ
ដែរ កាលព្រះរាជានោះធ្វើចោរកម្ម អ្នកណាទៅ
ការពារបាន សូមព្រះអង្គទ្រង់ជ្រាបចុះ ។ ព្រះរាជា
ត្រាស់ថា នៃមាណព អ្នកចូរទៅចាប់ចោរឲ្យយើង ។
ពេលនោះ ព្រះពោធិសត្វបាននាំឧទាហរណ៍មកថ្វាយ
ព្រះរាជាមួយរឿងទៀតថា ៖

បពិត្រមហារាជ ឯស្រុករបស់អ្នកស្រុកកាសី
មួយ មានស្ទឹងដែលមានក្រពើរបឹងរីងរូសកាចអាក្រក់
នៅខាងក្រោយផ្ទះនៃត្រកូលមួយ ហើយត្រកូលនោះ
មានបុត្រមួយប៉ុណ្ណោះ កាលឪពុករបស់គេស្លាប់ទៅ
បានបដិបត្តិមាតា ។ មាតារបស់គេបាននាំកុលធីតា

ម្នាក់មកឲ្យគេ ដោយដែលគេមិនប្រាថ្នាផងនោះ ។ ដំបូង ៗ នាងកុលធីតានោះស្រឡាញ់ យកចិត្តទុកដាក់បម្រើម្តាយក្មេកខ្លាំងណាស់ ។ ខាងក្រោយ នាងចម្រើនដោយបុត្រនិងធីតា ទើបចង់បណ្តេញម្តាយក្មេកចេញអំពីផ្ទះ សូម្បីមាតារបស់នាងក៏នៅក្នុងផ្ទះនោះដែរ ។ ពេលនោះ នាងពោលទោសម្តាយដោយប្រការផ្សេងៗ ចំពោះមុខស្វាមី ហើយពោលថា ខ្ញុំមិនអាចនឹងនៅចិញ្ចឹមមើលថែមាតារបស់បងបានទៀតទេ ចូរសម្លាប់មាតារបស់បងចោលទៅ កាលស្វាមីរបស់នាងពោលថា ការសម្លាប់មនុស្សជាកម្មធ្ងន់ណាស់ ខ្ញុំនឹងសម្លាប់ម្តាយរបស់ខ្ញុំបានយ៉ាងណា ក៏ពោលថា នៅពេលដែលគាត់ដេកលក់យើងជួយគ្នានាំគាត់ទៅទាំងគ្រែ បោះចុះទៅក្នុងស្ទឹងដែលមានក្រពើ ក្រពើ

នឹងស៊ីគាត់ហើយ ។ ស្វាមីរបស់នាងសួរថា ម្ដាយរបស់អូនដេកកន្លែងណា ។ នាងឆ្លើយថាគាត់ដេកនៅជិតម្ដាយរបស់បងនោះឯង ។ ស្វាមីរបស់នាងពោលថា បើដូច្នេះ អូនចូរទៅយកខ្សែចងគ្រែ ដែលម្ដាយរបស់ខ្ញុំគាត់ដេកធ្វើជាគ្រឿងសម្គាល់ ។ ពេលនោះ នាងក៏ធ្វើដូច្នោះហើយប្រាប់ថា ខ្ញុំបានធ្វើគ្រឿងសម្គាល់ទុកហើយ ។ ស្វាមីរបស់នាងពោលថា រង់ចាំបន្តិច ឲ្យមនុស្សម្នាទាំងឡាយគេដេកលក់អស់សិន ។ ខ្លួនឯងក៏ដេកធ្វើដូចជាលក់ ហើយទៅស្រាយខ្សែនោះមកចងគ្រែរបស់ម្ដាយភរិយា ហើយទៅដាស់ភរិយាឲ្យក្រោកឡើង ហើយទាំងពីរនាក់ក៏ជួយគ្នាសែងទាំងគ្រែ យកទៅបោះក្នុងទឹក ។ ក្រពើទាំងឡាយបានដណ្ដើមគ្នាស៊ីម្ដាយរបស់ស្ត្រីនោះ ក្នុងស្ទឹងនោះ ។

# បទកុសលមាណវជាតក

ស្អែកឡើង នាងដឹងថា ម្ដាយត្រូវប្ដូរ ទើបពោលថា បងអើយ! ម្ដាយរបស់ខ្ញុំត្រូវសម្លាប់ហើយ តទៅនេះ បងចូរសម្លាប់ម្ដាយរបស់បងទៅ ។ កាលស្វាមីឆ្លើយថា យល់ព្រម ក៏ពោលថា យើងជួយគ្នាធ្វើដើងថ្ករក្នុងព្រៃស្មសាន ហើយចាប់គាត់ដាក់ចូលទៅក្នុងភ្លើងឲ្យស្លាប់ ។ ពេលនោះ អ្នកទាំង ២ បាននាំមាតាដែលកំពុងដេកលក់ទៅដាក់នៅក្នុងព្រៃស្មសាន។ ស្វាមីសួរភរិយាក្នុងព្រៃស្មសាននោះថា នាងនាំភ្លើងមកហើយឬ ។ ភរិយាឆ្លើយថា មិនបានយកមកទេ ព្រោះភ្លេច ។ បុរសដែលជាស្វាមីពោលថា បើដូច្នោះ នាងចូរទៅយកមក ។ ភរិយាពោលថា ខ្ញុំមិនអាចទៅតែម្នាក់ឯងបានទេ បើបងឯងទៅយកក៏អូនមិនអាចនៅទីនេះតែម្នាក់ឯងបានដែរ យើងទៅទាំង ២ នាក់ ។

# បទកុសលមាណវជាតក

កាលប្ដីប្រពន្ធទាំង ២ នាក់ ទៅជាមួយគ្នាហើយ ស្ត្រីចាស់ភ្ញាក់ឡើងព្រោះខ្យល់រំភើរដឹងថា ទីនេះជាព្រៃខ្មោច ក៏ពិចារណាថា ប្ដីប្រពន្ធទាំងពីរនាក់នេះគង់នឹងមានបំណងសម្លាប់យើង ប្រាកដជាទៅយកភ្លើងមកដុតយើង ហើយគិតថា វាមិនដឹងកម្លាំងរបស់យើងទេ លុះគិតដូច្នេះហើយ បានយកសាកសពមួយឲ្យដេកលើគ្រែ យកសំពត់ចាស់គ្របពីលើ ហើយខ្លួនឯងចូលល្អាងពួនសម្ងំនៅជិតព្រៃខ្មោចនោះឯង ។ ប្ដីនិងប្រពន្ធនាំភ្លើងមកហើយ ដុតសាកសពនោះ ដោយគិតថា ជាស្ត្រីចាស់នោះ ហើយក៏ចៀសចេញទៅ ។

ក៏ក្នុងកាលនោះ នៅក្នុងល្អាងលាក់ខ្លួននោះ មានចោរម្នាក់យករបស់ទៅទុកពីមុន ចោរនោះគិតថា យើងនឹងយករបស់នោះ ទើបបានមក ឃើញស្ត្រីចាស់គិតថា យល់ថាជាយក្ខិនី វត្ថុរបស់របររបស់មាន

អមនុស្សហួងហែងហើយ ទើបបានទៅនាំយកគ្រូខ្មោចមកម្នាក់ លុះគ្រូខ្មោចដើរពាយមន្តចូលទៅក្នុងល្អាង ។ ស្ត្រីចាស់ក៏ពោលនឹងគ្រូខ្មោចនោះថា ខ្ញុំមិនមែនជាយក្ខិនីទេ លោកចូរមកចុះ យើងទាំង ២ នាក់នឹងបរិភោគទ្រព្យនេះ ។ គ្រូខ្មោចនិយាយថា យើងនឹងជឿបានយ៉ាងណា ។ ស្ត្រីចាស់នោះនិយាយថា លោកចូរយកអណ្តាត របស់លោកដាក់លើអណ្តាតរបស់យើងទៅ ។ គ្រូខ្មោចបានធ្វើដូច្នោះ ។ ភ្លាមនោះឯងស្ត្រីចាស់នោះបានខាំអណ្តាតគ្រូខ្មោចដាច់ធ្លាក់ចុះ។ គ្រូខ្មោចមានឈាមហូរចេញពីអណ្តាត គិតថាស្ត្រីចាស់នេះជាយក្ខិនីច្បាស់ណាស់ ក៏ស្រែករត់ជៀសចេញទៅ ។ ចំណែកស្ត្រីចាស់នោះ លុះស្អែកឡើងក៏ស្លៀកសំពត់សាច់ម៉ដ្ឋរលីងស្អាត កាន់យកកណ្តៈរតនៈផ្សេងៗ ទៅផ្ទះ ។ ពេលនោះ ស្ត្រីកូនប្រសាឃើញដូច្នោះ ក៏សួរថា ម៉ែចាំ ម៉ែបានរបស់នេះអំពីណា ។

ស្ត្រីចាស់នោះឆ្លើយថា អ្នកដែលត្រូវដុតលើជើងថ្ករក្នុងព្រៃខ្មោចនោះ រមែងបានទ្រព្យសម្បត្តិបែបនេះ ។ ស្ត្រីដែលជាកូនប្រសាសួរថា ម៉ែចាំ បើដូច្នោះ ខ្ញុំនេះអាចនឹងបានឬទេ ។ ស្ត្រីចាស់នោះឆ្លើយថា បើធ្វើដូចជាយើង នឹងបាន ។ ពេលនោះ ដោយអំណាចការចង់បានកណ្ដៈខ្លាំងពេក នាងបានប្រាប់ស្វាមីហើយឲ្យដុតខ្លួនក្នុងព្រៃខ្មោចនោះ ។ ថ្ងៃស្អែកឡើង ស្វាមីមិនឃើញភរិយាត្រឡប់មក ក៏សួរម្ដាយថា ម៉ែ ក្នុងវេលាពេលនេះ ម៉ែមក, ប៉ុន្តែកូនប្រសារបស់ម៉ែ ហេតុដូចម្ដេច មិនឃើញមក ។ ស្ត្រីចាស់ស្ដាប់ដូច្នោះ ក៏គំរាមកូនប្រុសថា អាឆ្កួតដែលឈ្មោះថា មនុស្សស្លាប់ហើយ នឹងមកបានដោយរបៀបណា ហើយពោលគាថា ថា

យមានយី សោមនស្សំ
មាលិនី ចន្ទនុស្សនំ

# បទកុសលមាណវជាតក

សា មំ ឃរា ជីច្ចកតិ
ជាតំ សរណតោ ភយំ ។

អញមានចិត្តសោមនស្ស ហើយនាំមកនូវកូនប្រុសស្រីណា ដែលប្រដាប់ដោយកម្រងផ្កា នឹងប្រោះព្រំដោយខ្លឹមចន្ទន៍ ( ឥឡូវ ) កូនប្រុសស្រីនោះបណ្ដេញអញចេញអំពីផ្ទះ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

មានអធិប្បាយថា យើងយល់ថា បុត្ររបស់យើងនឹងចម្រើនដោយបុត្រធីតាទាំងឡាយ ព្រោះអាស្រ័យស្ត្រីនេះ យើងនាំស្ត្រីណា ដែលមានសោមនស្ស បំពាក់កម្រងផ្កា មានកាយប្រោះព្រំដោយខ្លឹមចន្ទន៍លឿងមកប្រដាប់តុបតែងឲ្យជាកូនប្រសាសង្ឃឹមថា នឹងចិញ្ចឹមមើលថៃយើង នៅពេលដែល

យើងចាស់ ប៉ុន្តែស្ត្រីនោះ បានបណ្តេញយើងចេញអំពីផ្ទះ ថ្ងៃនេះភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

ព្រះពោធិសត្វ ក្រាបទូលតទៅថា បពិត្រមហារាជ ព្រះរាជាជាទីពឹងនៃមហាជន ដូចស្ត្រីកូនប្រសាជាទីពឹងរបស់ម្តាយក្មេក កាលភ័យកើតអំពីព្រះរាជានោះហើយ អ្នកណាអាចនឹងធ្វើអ្វីបាន សូមព្រះអង្គទ្រង់ជ្រាបចុះ ។ ព្រះរាជាទ្រង់សណ្តាប់ដូច្នោះហើយ ទ្រង់ត្រាស់ថា ម្នាលមាណព ហេតុការណ៍ដែលឯងនាំមកនេះ យើងមិនដឹង អ្នកចូរប្រគល់ចោរឲ្យយើងចុះ ។ ព្រះពោធិសត្វគិតថា យើងនឹងរក្សាកិត្តិយសព្រះរាជា ទើបបាននាំរឿងមកក្រាបទូលមួយរឿងទៀតថា

បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលមុន មានបុរសម្នាក់នៅក្នុងនគរនេះឯង តាំងសេចក្តីប្រាថ្នាហើយ ក៏បានបុត្រ ពេលដែលបុត្រកើតហើយ មាន

# បទកុសលមាណវជាតក

*បីតិសោមនស្សថា យើងបានបុត្រហើយ ចិញ្ចឹមកូន នោះដោយល្អ កាលកូនចម្រើនវ័យហើយ បានរក ភរិយាឲ្យ ក្រោយមក គាត់ក៏ចាស់ជរា មិនអាចធ្វើ ការងារបាន ពេលនោះ បុត្ររបស់គាត់បានពោលនឹង គាត់ថា ពុកមិនអាចធ្វើការងារបាន ចូរចេញអំពីផ្ទះ នេះទៅ លុះពោលដូច្នេះហើយ ក៏បណ្តេញគាត់ចេញ អំពីផ្ទះ បុរសចាស់នោះ ដើរសូមទានគេចិញ្ចឹមជីវិត ដោយលំបាកមែនទែន គាត់សោកខ្សឹកខ្សួលពោល គាថា ថា*

យេន ជាតេន នន្ទិស្សំ
យស្ស ច ភវមិច្ឆិសំ
សោ មំ ឃរា និច្ឆុភតិ
ជាតំ សរណតោ ភយំ ។

*អញត្រេកត្រអាលនឹងកូនប្រុសណាដែលកើត ហើយ នឹងប្រាថ្នាសេចក្តីចម្រើន ដល់កូនប្រុសណា*

# បទកុសលមាណវជាតក

(ឥឡូវ) កូនប្រុសនោះ បណ្តេញអញចេញអំពីផ្ទះ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

ព្រះពោធិសត្វក្រាបទូលតទៅថា បពិត្រមហារាជ ដែលឈ្មោះថាឪពុកដែលចាស់ជរា កូនដែលមានកម្លាំងគួរចិញ្ចឹមមើលថែរក្សាការពារយ៉ាងណា ជនបទទាំងអស់ ព្រះរាជាគួររក្សាដូច្នោះដែរ ក៏ឯភ័យនោះកាលកើតឡើងបានកើតឡើងហើយអំពីសម្នាក់ព្រះរាជាអ្នករក្សាសត្វទាំងពួង សូមព្រះអង្គទ្រង់ជ្រាបមនុស្សឈ្មោះឯណោះជាចោរដោយហេតុនេះ ។ ព្រះរាជាទ្រង់បានសណ្តាប់ដូច្នោះ ក៏ទ្រង់ត្រាស់ថា ម្នាលមាណព យើងមិនជ្រាបនូវហេតុដែលគួរ និងមិនគួរទេ អ្នកចូរបង្ហាញខ្លួនចោរមកចុះ ឬថា អ្នកខ្លួនឯងជាចោរ ។

ព្រះរាជាទ្រង់រំអុកព្រះពោធិសត្វរឿយៗ ដោយប្រការ ដូច្នេះ ។

ក្នុងកាលនោះ ព្រះពោធិសត្វក្រាបទូលព្រះ រាជាយ៉ាងនេះថា បពិត្រមហារាជ ព្រះអង្គនឹងឲ្យ ទូលព្រះបង្គំបង្ហាញមុខចោរតែម្យ៉ាងប៉ុណ្ណោះ ពិត មែនឬ ។ ព្រះរាជាទ្រង់ត្រាស់ ត្រូវហើយ ។ ព្រះ ពោធិសត្វក្រាបទូលថា បើដូច្នោះ ទូលព្រះបង្គំនឹង ប្រកាសកណ្ដាលបរិស័ទថា អ្នកឯណោះផង អ្នកនេះ ផងជាចោរ ។ ព្រះរាជាត្រាស់ថា ចូរធ្វើយ៉ាងនោះ ។ ព្រះពោធិសត្វបានស្ដាប់ហើយ គិតថា ព្រះរាជានេះ មិនឲ្យយើងរក្សាព្រះអង្គទេ ដូច្នោះយើងនឹងចាប់ចោរ ក្នុងពេលនេះ គិតដូច្នោះហើយ ក៏ប្រកាសហៅមហា ជនមកប្រជុំ ហើយពោលគាថា ២ គាថា ថា

**បទកុសលមាណវជាតក**

សុណន្តុ មេ ជានបទា

នេគមា ច សមាគតា

យតោទកំ តទាទិត្តំ

យតោ ខេមំ តតោ ភយំ ។

រាជា វិលុម្បតេ រដ្ឋំ

ព្រាហ្មណោ ច បុរោហិតោ

អត្តគុត្តា វិហរថ

ជាតំ សរណតោ ភយំ ។

*សូមឲ្យពួកអ្នកជនបទ និងអ្នកនិគម ដែលបាន មកប្រជុំ ស្តាប់ខ្ញុំ ( ឥឡូវ ) វត្ថុណាជាទឹក វត្ថុនោះ ក្លាយ ទៅជាភ្លើង សេចក្តីក្សេម កើតមកពីព្រះរាជាណា ភ័យ កើតមកអំពីព្រះរាជានោះហើយ ។*

# បទកុសលមាណវជាតក

ព្រះរាជានិងព្រាហ្មណ៍បុរោហិតបូន់ជនអ្នកនៅក្នុងដែន អ្នកទាំងឡាយចូររក្សាខ្លួន ដ្បិតភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

ពេលនោះ ប្រជាជនទាំងឡាយបានស្តាប់ពាក្យរបស់ព្រះពោធិសត្វនោះហើយ នាំគ្នាពោលថា ព្រះរាជាអង្គនេះសមគួរជាអ្នករក្សាការពារ ពេលនេះ ព្រះអង្គត្រឡប់ជាដាក់ទោសអ្នកដទៃ យកទ្រព្យរបស់ព្រះអង្គទៅទុកក្នុងស្រះបោក្ខណីដោយព្រះអង្គឯង ហើយស្វែងរកចោរ ពេលនេះ ពួកយើងនឹងសម្លាប់ព្រះរាជាលាមកនេះ ដើម្បីមិនឲ្យមានចោរកម្មតទៅទៀត ។ ពេលនោះ ប្រជាជនទាំងនោះក៏បានព្រមគ្នាក្រោកឡើង កាន់កំណាត់ឈើខ្លះ ដំបងខ្លះ វាយព្រះរាជានិងព្រាហ្មណ៍បុរោហិតឲ្យស្លាប់ ហើយអភិសេកព្រះពោធិសត្វឲ្យឡើងគ្រងរាជសម្បត្តិតទៅ ។

# បទកុសលមាណវជាតក

## ជាតកភាវសាន

ព្រះបរមសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងដូច្នះហើយ ទ្រង់ត្រាស់ថា ម្នាលឧបាសក ការចាំស្នាមជើងលើផែនដីបាននោះ មិនគួរឲ្យ អស្ចារ្យទេ បណ្ឌិតកាលពីមុន ចាំស្នាមជើងក្នុងអាកាសបានយ៉ាងនេះ ហើយទ្រង់ប្រកាសសច្ចធម៌ ពេលចប់សច្ចធម៌ ឧបាសកនិងបុត្របានសម្រេចសោតាបត្តិផល ព្រះទសពលទ្រង់ប្រជុំជាតកថា ឪពុកក្នុងកាលនោះបានមកជាកស្សប មាណពដែលឈ្លាសវៃក្នុងការសង្កេតស្នាមជើងនោះគឺ **តថាគត**នេះឯង៕

ចប់ បទកុសលមាណវជាតក ។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក នវកនិបាត បទកុសលមាណវជាតកវណ្ណនា បិដកលេខ ៥៩ ទំព័រ ១៤៦)